ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# តំបន់ឆ្នេរសមុទ្រថ្មស

សម្រាប់រយៈពេល០៣ឆ្នាំ (ខែកុម្ភៈ ឆ្នាំ២០២២-ខែធ្នូ ឆ្នាំ២០២៤)

| | |
|---|---|
| សហគមន៍នេសាទ | :តំបន់ឆ្នេរសមុទ្រថ្មស |
| ភូមិ | : ស្រែថ្មី |
| ឃុំ | : ថ្មស |
| ស្រុក | : បូទុមសាគរ |
| ខេត្ត | : កោះកុង |

ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១

# មាតិកា


**១.ស្ថានភាពទូទៅ** ............ ១

**២.អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម** ............ ១

ក.ប្រជាពលរដ្ឋ............ ១

ខ.មុខរបរ............ ២

**៣.កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ............ ៣

ក.ទីតាំង............ ៣

ខ.ដែននេសាទ............ ៣

គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស............ ៣

ឃ. ធនធានជលផល............ ៣

ឃ.១.ប្រភេទត្រី............ ៣

ឃ.២.ប្រភេទវារីសត្វ............ ៤

**៤.ការធ្វើនេសាទ** ............ ៤

ក.អ្នកនេសាទ............ ៤

ខ.ឧបករណ៍នេសាទ............ ៤

គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ............ ៦

**៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ............ ៦

ក.ទស្សនៈវិស័យ............ ៦

ខ.គោលបំណង............ ៦

គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍............ ៧

គ.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ............ ៧

គ.២.ផែនការស្រង់ស្ថិតិឧបករណ៍ ទូកកាណូត និងផលនេសាទ............ ៧

គ.៣.ផែនការចុះល្បាត............ ៨

គ.៤.ផែនការបោះព្រំប្រទល់សហគមន៍នេសាទជាថ្មី............ ៨

គ.៥.ផែនការរៀបចំកន្លែងអភិរក្ស............ ៩

គ.៦.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម............ ១០

គ.៧.ផែនការអភិវឌ្ឍន៍ធនាគារក្តាមសេះ............ ១១

គ.៨.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ............ ១១

គ.៩.ផែនការពង្រីក និងអភិវឌ្ឍន៍មុខរបរចិញ្ចឹមជីវិតបន្ថែម............ ១២

គ.១០.ផែនការគ្រប់គ្រងកាកសំណល់ផ្លាស្ទិក និងសម្រាមផ្សេងៗ............ ១៣

គ.១១.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ....................១៣
គ.១២.ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ....................១៤
គ.១៣.ផែនការបង្កើតស្នាក់ការ និងបំពាក់សម្ភារៈ....................១៤
គ.១៤.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ....................១៥
ឃ.យុទ្ធសាស្ត្រ ....................១៥
**៦.ឧបសម្ពន្ធ**
ឧបសម្ពន្ធ ៖តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឆ្នាំ២០២២-២០២៤....................១៧
តារាងកម្មវិធីការងារសម្រាប់សហគមន៍នេសាទក្នុងរយៈពេល០៣ឆ្នាំ២០២២-២០២៤....................២១

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍តំបន់ឆ្នេរថ្មស

## ១.ស្ថានភាពទូទៅ

នៅឆ្នាំ២០០០រដ្ឋបាលជលផលបានធ្វើកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងវិស័យជលផល ដើម្បីឱ្យសមស្របជាមួយគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការដែលមានក្នុងជាយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដោយផ្តោតលើការកាត់បន្ថយភាពក្រីក្រតាមរយៈការផ្ទេរសិទ្ធិអំណាចដល់ប្រជាពលរដ្ឋដែលរស់ជនបទ ដើម្បីចូលរួមគ្រប់គ្រងធនធានជលផលនៅក្នុងមូលដ្ឋានរបស់ខ្លួនប្រកបដោយចីរភាព និងសមធម៌តាមបែបសហគមន៍នេសាទក្នុងគោលបំណងទទួលផលប្រយោជន៍ និងធ្វើឱ្យធនធានជលផលប្រសើរឡើងនៅមូលដ្ឋានរបស់ខ្លួន។ ភូមិតាមាយ ត្រូវបានរៀបចំសហគមន៍នេសាទដោយមានការចូលរួមយ៉ាងកុះករពីប្រជាពលរដ្ឋមូលដ្ឋាន។ សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មសត្រូវបានបង្កើតឡើងដោយមហាសន្និបាតលើកដំបូងនៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៥ ដោយបានគាំទ្រពីវិទ្យាស្ថានស្រាវជ្រាវអន្តរជាតិ (IDRC) ព្រមទាំងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រកាសទទួលស្គាល់នៅថ្ងៃទី២៦ខែធ្នូ ឆ្នាំ២០១១។ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍តំបន់ឆ្នេរសមុទ្រថ្មស បានរៀបចំបានដោយមានការគាំទ្របច្ចេកទេសពីក្រុមការងារខណ្ឌរដ្ឋបាលជលផលកោះកុង និងរដ្ឋបាលជលផលថ្នាក់កណ្តាល ព្រមទាំងកិច្ចសហការពីអាជ្ញាធរដែនដី និងបានគាំទ្រថវិកាពីគម្រោងEU។ ផែនការនេះនឹងអនុវត្តចាប់ពីខែកុម្ភៈ ឆ្នាំ២០២២ ដល់ ខែធ្នូ ឆ្នាំ២០២៤។

គណៈកម្មការសហគមន៍នេសាទ ត្រូវបានបោះឆ្នោតដែលមានសមាជិកគណៈកម្មការសហគមន៍នេសាទ មានចំនួន០៩នាក់ ក្នុងនោះស្ត្រីចំនួន០១នាក់ ព្រមទាំងបានអនុវត្តតួនាទី និងភារៈកិច្ចរបស់ខ្លួនដែលស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀងកន្លែងនេសាទ និងផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍។ ទន្ទឹមនឹងនេះ គណៈកម្មការសហគមន៍នេសាទបានកសាងសមត្ថភាពតាមរយៈការចូលរួមបណ្តុះបណ្តាល សិក្ខាសាលា ប្រជុំការងារ ទស្សនៈកិច្ចសិក្សា និងរៀនសូត្រតាមឯកសារផ្សេងៗ។

គណៈកម្មការសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មស បានរៀបចំសកម្មភាពសំខាន់ៗ ដើម្បីឱ្យសហគមន៍នេសាទមានផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍សម្រាប់អនុវត្ត និងបង្កលក្ខណៈឱ្យសហគមន៍នេសាទអាចស្វែងរកថវិកាអនុវត្តការងារសកម្មភាពរបស់ខ្លួន ដើម្បីជួយដល់ការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទសហគមន៍ ព្រមទាំងប្រជាពលរដ្ឋមូលដ្ឋានទទួលបានផលប្រយោជន៍ពីការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព និងសមធម៌។

## ២.អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក.ប្រជាសាស្ត្រ

នៅពេលបច្ចុប្បន្ន សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មសមានប្រជាពលរដ្ឋសរុបចំនួន២២១៣គ្រួសារ ហើយមានមនុស្សចំនួន៩០៩០នាក់ ក្នុងនោះស្ត្រីមានចំនួន៤៥៩២នាក់។ ផ្អែកតាមការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្របង្ហាញថា គ្រួសារដែលស្ថិតក្នុងស្ថានភាពក្រីក្រ១មានចំនួន១៥៧គ្រួសារ និងស្ថានភាពក្រីក្រ២មានចំនួន១២៤គ្រួសារដែលសរុបចំនួន២៨១គ្រួសារ។ ប្រជាពលរដ្ឋនៅក្នុងសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មសចំនួន០៧

គ្រួសារគោរពសាសនាឥស្លាមក្រៅពីនោះប្រជាពលរដ្ឋគោរពព្រះពុទ្ធសាសនា ហើយស្ថានភាពទូទៅរបស់ប្រជាជននៅក្នុងសហគមន៍នេសាទនេះ មានដូចជា៖

- ស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមានចំនួន៥៧នាក់
- បុរសពោះម៉ាយក្នុងសហគមន៍នេសាទមានចំនួន៤៣នាក់
- ជនពិការក្នុងសហគមន៍នេសាទមានចំនួន៣៦នាក់ ក្នុងនោះស្ត្រីមានចំនួន១៧នាក់
- កុមារកំព្រាក្នុងសហគមន៍នេសាទមានចំនួន៣០នាក់ ក្នុងនោះកុមារីមានចំនួន២០នាក់
- ចាស់ជរាក្នុងសហគមន៍នេសាទមានចំនួន៦៦នាក់ក្នុងនោះស្ត្រីមានចំនួន៤០នាក់
- អ្នកមានជម្ងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមានចំនួន០៤នាក់ ក្នុងនោះស្ត្រីមានចំនួន០៣នាក់
- តាមរបាយការណ៍របស់ក្រុមប្រឹក្សាឃុំបង្ហាញថា នៅក្នុងសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មីស អ្នកដែលមិនចេះអក្សរមានចំនួន៤៩៤នាក់ ក្នុងនោះស្ត្រីមានចំនួន២៥១នាក់ ។

ខ.មុខរបរ

តាមរបាយការណ៍របស់ក្រុមប្រឹក្សាឃុំបានបញ្ជាក់ថា ប្រជាពលរដ្ឋក្នុងសហគមន៍តំបន់ឆ្នេរសមុទ្រថ្មីសពឹងផ្អែកលើការធ្វើនេសាទជាចំបង បន្ទាប់មក ការកែច្នៃផលនេសាទ រីឯស្ត្រីគ្រាន់តែជាអ្នកប្រកបមុខរបរបន្ទាប់បន្សំដូចជា៖ លក់ដូរជាដើម។ កន្លងមក រដ្ឋបាលជលផល និងអង្គការដៃគូអភិវឌ្ឍន៍បានជួយបណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រីលក្ខណៈគ្រួសារ និងការចិញ្ចឹមសត្វ ព្រមទាំងការចិញ្ចឹមជីវិតផ្សេងៗដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន។

ពេលបច្ចុប្បន្ន នៅក្នុងសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មីសប្រជាពលរដ្ឋមានស្ថានភាពនៃការចិញ្ចឹមជីវិត និងមុខរបរសំខាន់ៗ រួមមាន៖

| ល.រ | ប្រភេទមុខរបរ | ចំនួនគ្រួសារ | សំគាល់ |
|---|---|---|---|
| ១ | អ្នកធ្វើនេសាទ | ១៦៦០ | មុខរបរចំបង |
| ២ | អ្នកដឹកជញ្ជូនផលនេសាទ | ០៧ | |
| ៣ | អ្នកកែច្នៃផលនេសាទ | ៨៥ | |
| ៤ | អ្នកជួសជុលឧបករណ៍នេសាទ | ១២ | |
| ៥ | ជាងជួសជុលទូក | ០៦ | |
| ៦ | អ្នកដឹកជញ្ជូនភ្ញៀវ | ០៩ | |
| ៧ | អ្នកចិញ្ចឹមសត្វលក្ខណៈគ្រួសារ | ១៥ | |
| ៨ | ជាងសំណង់ | ២៥ | |
| ៩ | អ្នកលក់ដូរ | ៣៣២ | |
| ១០ | ជាងជួសជុលម៉ូតូ | ១៨ | |
| ១១ | កម្មករលក់ពលកម្ម | ៣៥ | |

### ៣.កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងដែននេសាទសហគមន៍

#### ក.ទីតាំង

សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មសមានទីតាំងស្ថិតក្នុងភូមិស្រែថ្មី ឃុំថ្មស ស្រុកបូទុមសាគរ ខេត្តកោះកុង ។ ទីតាំងរបស់សហគមន៍នេសាទនេះ ត្រូវបានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ប្រកាសទទួលស្គាល់នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១។ ដូចនេះ សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មស មានព្រំប្រទល់ដូចជា៖

- ខាងជើងទល់នឹងភូមិតាមាឃ
- ខាងត្បូងទល់នឹងពាមក្បៀនទឹក
- ខាងកើតទល់នឹងឆកសមុទ្រកំពង់សោម
- ខាងលិចទល់នឹងព្រៃកោងកាងក្នុងឃុំ។

#### ខ.ដែននេសាទ

សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មសជាដែននេសាទសាធារណៈរបស់រដ្ឋ ហើយក្នុងកន្លែងនេសាទសហគមន៍ស្ថិតតាមតំបន់ឆ្នេរសមុទ្រ។ សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មស មានទំហំ១១.២២០ហិកតា។

#### គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មស បានសម្រេចបង្កើតកន្លែងអភិរក្សចំនួន០២កន្លែងដែលមានសក្ដានុពលក្នុងការអភិរក្សគ្រែងឈាម ផ្កាថ្ម ស្មៅសមុទ្រ និងត្រីមេពូជ។ ដូចនេះផងដែរ កន្លែងអភិរក្សទាំពីរនេះ ត្រូវបានធ្វើការគ្រប់គ្រងដោយសមាជិកសហគមន៍នេសាទមានដូចខាងក្រោម៖

| ល.រ | ឈ្មោះកន្លែងអភិរក្ស | ទំហំជាហិកតា | ការអភិរក្ស |
|---|---|---|---|
| ១ | ព្រែកភាកធំ ដល់ជញ្ជាំងស៊ីព្រែកតាតី | ៤៤០ | កន្លែងអភិរក្សគ្រែងឈាម |
| ២ | ឃ្លោងស្រែត្រាវដល់ ជ្រោយជំបូរ | ២២៦.៦៤ | ជំរកសុវត្ថិភាពធនធានជលផលចម្រុះ |

#### ឃ.ធនធានជលផល

នៅក្នុងប្រទេសកម្ពុជា ធនធានជលផលបានដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង ដោយផ្នែក ត្រីអាចផ្ដល់ជាអាហារដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ។ តាមការបង្ហាញពីគណៈកម្មការ និងសមាជិក សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មសបានឱ្យដឹងថា ពេលបច្ចុប្បន្ននេះ ធនធានជលផលក្នុងសមុទ្រមិនមានការកើនឡើងទេដោយសារមានការប្រែប្រួលអាកាសធាតុ និងកត្តាមនុស្ស។ ផ្អែកតាមការអង្កេតរបស់ក្រុមការងារ គណៈកម្មការ និងសមាជិកសហគមន៍លើធនធានជលផលក្នុងសហគមន៍នេសាទនេះមានដូចជា៖

##### ឃ.១.ប្រភេទត្រីសមុទ្រ:

ក្នុងសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មសមានប្រភេទត្រីដូចជា៖ ត្រីស ត្រីក្បាលហែង ត្រីអាំងកើយ ត្រីបេកា ត្រីតុកកែ ត្រីចាប ត្រីអង្រែ ត្រីកិ ត្រីពួច ត្រីចង្កមបី ត្រីក្ដិន ត្រីក្បូក ត្រីម្រេច ត្រីឆ្លង់ ត្រីផ្ទោង ត្រីឆ្លាម ត្រីប្រលូស ត្រីក្អុក ត្រីអាម៉ក់ ត្រីបបែល ត្រីអណ្ដាតឆ្កែ ត្រីអូច ត្រីឆ្មារ ត្រីកំពត ត្រីគោ ត្រីការ៉ាវ ត្រីជូអង្គរ ត្រីផ្ទក់សមុទ្រ ត្រីអណ្ដែងប៉ុយ ត្រីកាម៉ុង ត្រីកន្ទុយក្រពី ត្រីកាតាំង ត្រីស្លឹកឫស្សី ត្រីកន្ទុយរឹង ត្រីអណ្ដែងខ្លុយ។

ឃ.២.ប្រភេទវារីសត្វសមុទ្រ:

ក្នុងសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មស មានប្រភេទវារីសត្វដូចជាៈ បង្គា ក្តាមសេះ ក្តាមថ្ម ក្តាមជ័រ ក្តាមព្រលិត ក្តាមប្រង់ ក្តាមថ្កលាន់ អន្លង់សមុទ្រ មឹក គ្រែងឈាម បង្កងកណ្តូប ខ្យងកំបោរ ខ្យងចាក់ច្រែង ខ្យងភ្លែកប្រើស ខ្យងដីរុំ ខ្យងបន្លា ខ្យងផ្ញើប្រាណ ខ្យងរៀចមាត់ ងាវភក់ គ្រំក្រឡា ហូល និងប្រភេទសត្វជិតផុតពូជមានដូចជាៈកញ្ច ផ្សោតខ្មៅ ប៉ាឡាំងកាស ផ្សោតប៉ាភ៉ា បង្កុយ។ល។

## ៤.ការធ្វើនេសាទ

### ៤.ក.អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន៦០០នាក់ ក្នុងនោះស្ត្រីមានចំនួន២៣០នាក់។
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន១៦១៣នាក់។
- តាមការប៉ាន់ស្មានអ្នកនេសាទដែលមកពីខាងក្រៅ ហើយមិនមែនជាសមាជិកមានចំនួន២២០នាក់ ក្នុងនោះស្ត្រីចំនួន២៥នាក់ ក្នុង១ឆ្នាំ។

### ៤.ខ.ឧបករណ៍នេសាទ

ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទដែលប្រើប្រាស់មានដូចជាៈ

ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទដែលប្រើប្រាស់ក្នុងសហគមន៍មានដូចជាៈ

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ/ចំនួន | ក្រឡា | រដូវនេសាទ |
|---|---|---|---|---|---|
| ១ | លបក្តាម | លប | ៥០០ | | ពេញមួយឆ្នាំ |
| ២ | មងត្រីក្បក | ម៉ែត្រ | ៣០០ | ក្រឡា ៣.៥ស.ម ឡើង | ពេញមួយឆ្នាំ |
| ៣ | រនងមឹកសំបកខ្យង | សំបក | ១០០០ | | ពេញមួយឆ្នាំ |
| ៤ | មងបង្គា | ម៉ែត្រ | ៥០០ | ក្រឡា៣.៥ស.ម ឡើង | ពេញមួយឆ្នាំ |
| ៥ | មងត្រីកាម៉ុង | ម៉ែត្រ | ៣០០ | ក្រឡា៤ស.ម ឡើង | ពីខែ១០ ដល់ ខែ១២ |
| ៦ | មងក្តាម | ម៉ែត្រ | ៥០០ | ក្រឡា៨ស.ម ឡើង | ពីខែ១០ ដល់ ខែ០៦ |
| ៧ | មងត្រីសំបាន់ | ម៉ែត្រ | ២០០ | ក្រឡា ៨ ស.មឡើង | ពីខែ០៦ ដល់ ខែ១០ |
| ៨ | សន្ទូចរនងត្រីក្ដក | ថ្នេ | ៥០០ | | ពីខែ០៦ ដល់ ខែ១០ |
| ៩ | មងត្រីកាវ៉ | ម៉ែត្រ | ៦០០ | ក្រឡា ៧ សម | ពីខែ០៦ ដល់ ខែ១០ |
| ១០ | មងត្រីកាតាង | ម៉ែត្រ | ២០០ | ក្រឡា ៨ សម | ពីខែ០៦ ដល់ ខែ១០ |
| ១១ | មងបង្កងកណ្តូប | ម៉ែត្រ | ១០០០ | ក្រឡា ៨ ស.ម | ពីខែ១១ ដល់ ខែ០៤ |
| ១២ | មងត្រីបេកា | ម៉ែត្រ | ៥០០ | ក្រឡា ៥ សម | ពីខែ០៦ ដល់ខែ១០ |

| ល.រ | ប្រភេទទូក-កាណូត | ចំនួន(គ្រឿង) | ចំណុះ(គ.ក្រ) | កំលាំងសេះ |
|---|---|---|---|---|
| ១ | ទូកមានម៉ាស៊ីនបន្ទោត | ១៨៣ | ៥០០-១០០០ | ៦-២២ |
| ២ | ទូកមានម៉ាស៊ីនបាត | ៣៣០ | ៨០០-១.៥០០ | ២២-៣៥ |

ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍នៅក្នុងសហគមន៍នេសាទ

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ/ចំនួន | ក្រឡាមង | រដូវនេសាទ |
|---|---|---|---|---|---|
| ១ | មងបង្គា | ម៉ែត្រ | ៥០០ | ក្រឡា៣.៨ស.ម ឡើង | ពេញមួយឆ្នាំ |
| ២ | មងត្រីកាម៉ុង | ម៉ែត្រ | ៣០០ | ក្រឡា៤ស.ម ឡើង | ពីខែ១០ ដល់ ខែ១២ |
| ៣ | មងក្តាម | ម៉ែត្រ | ៥០០ | ក្រឡា ៨ ស.ម ឡើង | ពីខែ១០ ដល់ ខែ០៦ |
| ៤ | មងត្រីកាតាំង | ម៉ែត្រ | ២០០ | ក្រឡា ៨ ស.ម ឡើង | ពីខែ០៦ ដល់ ខែ១០ |
| ៥ | មងបង្កងកណ្តប | ម៉ែត្រ | ១០០០ | ក្រឡា ៨ ស.ម ឡើង | ពីខែ១១ ដល់ ខែ០៤ |
| ៦ | មងត្រីបេកា | ម៉ែត្រ | ៧០០ | ក្រឡា ៥ ស.ម ឡើង | ពីខែ០៦ ដល់ ខែ១០ |

| ល.រ | ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ | កំលាំងសេះ |
|---|---|---|---|---|
| ១ | ទូកមានម៉ាស៊ីនបាត | ៦៥ | ១០០០-១៥០០ គ.ក្រ | ២២-៣០ |
| ២ | ទូកម៉ាស៊ីនបន្តើត | ១៥ | ៥០០-៨០០០ គ.ក្រ | ៦-២២ |

ឧបករណ៍នេសាទ ទូក និងកាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ/ចំនួន | ក្រឡាមង | រដូវនេសាទ |
|---|---|---|---|---|---|
| ១ | មងបង្គា | ម៉ែត្រ | ៥០០ | ក្រឡា៣.៨ស.ម ឡើង | ពេញមួយឆ្នាំ |
| ២ | មងត្រីកាម៉ុង | ម៉ែត្រ | ៣០០ | ក្រឡា៤ស.ម ឡើង | ពីខែ១០ ដល់ ខែ១២ |
| ៣ | មងក្តាម | ម៉ែត្រ | ៥០០ | ក្រឡា ៨ ស.ម ឡើង | ពីខែ១០ ដល់ ខែ០៦ |
| ៤ | មងត្រីកាតាំង | ម៉ែត្រ | ២០០ | ក្រឡា ៨ ស.ម ឡើង | ពីខែ០៦ ដល់ ខែ១០ |
| ៥ | មងបង្កងកណ្តប | ម៉ែត្រ | ១០០០ | ក្រឡា ៨ ស.ម ឡើង | ពីខែ១១ដល់ ខែ០៤ |

| ល.រ | ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ | កំលាំងសេះ |
|---|---|---|---|---|
| ១ | ទូកម៉ាស៊ីន | ២៥ | ១០០០-១៥០០ | ២៤-៣៥ |

គ.ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ល.រ | ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គិតជាគក្រ) | | |
|---|---|---|---|---|
| | | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ១ | លបក្តាម | ៨០ | ៧០ | ១៥ |
| ២ | មងក្តាមថ្ម | ២៥០ | ៣៥០ | ៦០០ |
| ៣ | មងត្រីក្បក | ២០០ | ២៦០ | ៤៦០ |
| ៤ | មងត្រីកាវ៉ាវ | ០ | ២២៥ | ២២៥ |
| ៥ | មងបង្គា | ៣០០ | ៤៥០ | ៧៥០ |
| ៦ | មងបង្កងកណ្តុប | ១៦០ | ០ | ១៦០ |
| ៧ | មងត្រីកាម៉ុង | ៦០០ | ០ | ៦០០ |
| ៨ | មងត្រីសំប៉ាន់ | ០ | ១៥០ | ១៥០ |
| ៩ | សន្ទូចរនងត្រីក្អុក | ០ | ២៤០ | ២៤០ |
| ១០ | មងត្រីកាតាំង | ០ | ៣៤០ | ៣៤០ |
| ១១ | រនងមឹកសំបកខ្យង | ៦២០ | ៥០០ | ១០២០ |
| ១២ | មងត្រីបេកា | ០ | ២៤០ | ២៤០ |

## ៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ក.ទស្សនៈវិស័យ

សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មីសមានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ.គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទសមុទ្រជាកន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណីក្នុងរដូវទឹកជោរ និងព្រៃកោងកាង និងការគ្រប់គ្រងកន្លែងអន្លង់អភិរក្ស។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍន៍ចំរុះ។
- ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ច្បាស់ និងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

គោលបំណង

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍តំបន់ឆ្នេរសមុទ្រថ្មសគឺ រៀបចំឡើងដោយបានគិតគូរអំពីប្រភេទដែននេសាទ ប្រភេទទំហំ ប្រវែង ចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ និងការប៉ាន់ប្រមាណផលស្តុកដែលមាននៅក្នុងដែននេសាទ ដោយធ្វើយ៉ាងណាមិនឱ្យការធ្វើនេសាទលើសពីតម្រូវការធនធានជលផលដែលមានក្នុងកន្លែងសហគមន៍នេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

ទីតាំង ឬកន្លែងនេសាទ

| ល.រ | ឈ្មោះទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | |
|---|---|---|---|---|
| | | | ប្រភេទ | ទំហំ/ប្រវែង |
| ១ | ដែននេសាទផ្សេងៗក្រៅពីតំបន់អភិរក្សរបស់សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មស | ផ្អែកតាមប្រភេទត្រី | លបក្តាម មងក្តាមថ្ម-សេះ-ក្តាមជ័រ មងត្រី-ក្បក-ឆ្តង់-កាតាំង-កាភ័រ-កាម៉ុង-ត្រីក្បកត្រីសំប៉ាន់-កាតាំង-បង្គា និងរងមឹកសំបកខ្យង។ល។ | អនុវត្តតាមប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទលេខ៣១៩ ប្រក.កសក ចុះថ្ងៃទី២៩ខែមិថុនា ឆ្នាំ២០១៥។ |

សំគាល់: ត្រូវអនុវត្តតាមប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ៣១៩ ប្រក.កសក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកំណត់ប្រភេទឧបករណ៍ដែលអនុញ្ញាតិឱ្យធ្វើនេសាទក្នុងដែននេសាទសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា។

#### គ.២.ផែនការស្រង់ស្ថិតិឧបករណ៍ ទូកកាណូត និងផលនេសាទ

ផែនការស្រង់ស្ថិតិឧបករណ៍ ទូកកាណូត និងផលនេសាទ ត្រូវបានរៀបចំឡើងដូចមានក្នុងតារាងខាងក្រោម ៖

| ល.រ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(រៀល) | ថ្ងៃ/ខែ/ឆ្នាំចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ១ | បង្កើតកម្រងបញ្ជីរសំណួរ | ៥០០ ០០០ | ០១/០៨/២០២២ | ១០/០៨/២០២២ |
| ២ | បណ្តុះបណ្តាលក្រុមការងារ | ១ ៥០០ ០០០ | ១០/០៨/២០២២ | ២០/០៨/២០២២ |
| ៣ | ចុះស្រង់ស្ថិតិឧបករណ៍នេសាទ | ៣ ៥០០ ០០០ | ២០/០៨/២០២២ | ៣០/១១/២០២២ |
| ៤ | ចងក្រងទិន្នន័យ | ៥០០ ០០០ | ១/១២/២០២២ | ៣០/១២/២០២២ |

គ.៣.ផែនការចុះល្បាត

ជាទូទៅ ការចុះល្បាតជាភារកិច្ចរបស់គណៈកម្មការ និងសមាជិកសហគមន៍ ប៉ុន្តែការចុះល្បាតនេះគឺផ្អែកលើការជួយឧត្ថម្ភពីដៃគូអភិវឌ្ឍន៍។ កន្លងមក ការចុះល្បាតលើកន្លែងនេសាទសហគមន៍បានអនុវត្តតិចតួច ពីព្រោះជាខ្វះមធ្យោបាយល្បាត។ ដូចនេះ គណៈកម្មការ និងសមាជិកសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មីសបានគ្រោងរៀបចំផែនការល្បាតក្នុងគោលបំណងដូចជាៈ

- ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់
- សមាជិកអាចទទួលបានផលនេសាទពីកន្លែងនេសាទសហគមន៍
- គ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព។

ផែនការចុះទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោមៈ

| លរ | សកម្មភាព | ថវិកាប្រមាណតម្លៃ(រៀល) | អ្នកចូលរួម | ថ្ងៃ/ខែ/ឆ្នាំចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| ១ | ប្រជុំពិភាក្សាលើការរៀបចំផែនការល្បាត | ៥០០ ០០០ | គណៈកម្មការ ជំនាញជលផល | ២០២២ | ២០២៤ |
| ២ | រៀបចំមធ្យោបាយ និងសម្ភារៈ<br>• សាំង និងប្រេងបាត<br>• អាវភ្លៀង អាវពោង ពិល មួក<br>• កាតទូរស័ព្ទ អាយកូមទាក់ទង<br>• ម៉ាស៊ីនថត កែវយឹត<br>• ទូកម៉ាស៊ីនមួយគ្រឿង | ៩ ០០០ ០០០ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | ២០២២ | ២០២៤ |
| ៣ | ប្រជុំផ្សព្វផ្សាយផែនការល្បាតដល់អ្នកពាក់ព័ន្ធ | ១ ០០០ ០០០ | ជំនាញជលផល និងស្ថាប័នពាក់ព័ន្ធ | ២០២២ | ២០២៤ |
| ៤ | អនុវត្តផែនការ និងកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋានជលផល និងជំនាញពាក់ព័ន្ធ | ១ ៥០០ ០០០ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល | ២០២២ | ២០២៤ |

គ.៤.ផែនការបោះព្រំប្រទល់សហគមន៍នេសាទជាថ្មី

កន្លែងនេសាទសហគមន៍តំបន់ឆ្នេរសមុទ្រថ្មីសចាំបាច់ត្រូវតែរៀបចំបោះបង្គោលព្រំប្រទល់សារជាថ្មី ព្រមទាំងធ្វើបាណ្ណផ្សព្វផ្សាយ ក្តារខៀនព័ត៌មាន បិទផ្សាយបទបញ្ញត្តិផ្សេងៗសម្រាប់កន្លែងនេសាទសហគមន៍នេះ ដោយត្រូវសាងសង់រោងយាមសម្រាប់ក្រុមល្បាតបំពេញការងារ។

ផែនការបោះព្រំប្រទល់សហគមន៍នេសាទសារជាថ្មី ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(រៀល) | អ្នកចូលរួម | ថ្ងៃ/ខែ/ឆ្នាំចាប់ផ្ដើម | ថ្ងៃ/ខែ/ឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| ១ | ប្រជុំពិភាក្សាកំណត់ទំហំបង្គោល | ២០០ ០០០ | គណៈកម្មការ និងអ្នកពាក់ព័ន្ធ | ០១/២/២០២២ | ០២/២/២០២២ |
| ២ | រៀបចំ និងសាងសង់បង្គោលចំនួន១៦ដើម | ៦ ០០០ ០០០ | គណៈកម្មការ និងអ្នកពាក់ព័ន្ធ | ១០/២/២០២២ | ៣០/២/២០២២ |
| ៣ | បោះបង្គោលព្រំប្រទល់សហគមន៍នេសាទ | ២ ០០០ ០០០ | គណៈកម្មការ និងអ្នកពាក់ព័ន្ធ | ១៥/៣/២០២២ | ២៦/៣/២០២២ |
| ៤ | ត្រួតពិនិត្យ-តាមការអនុវត្ត | ៥០០ ០០០ | អ្នកពាក់ព័ន្ធ | ១៥/៥/២០២២ | ២០២៤ |

### ៨.៥.ផែនការរៀបចំកន្លែងអភិរក្ស

សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មស បានសម្រេចបង្កើតកន្លែងអភិរក្ស០២កន្លែងគឺ កន្លែងអភិរក្សព្រៃភក់ធំដែលមានទំហំ៤០០ហិកតា និងកន្លែងអភិរក្សឃ្លោងស្រែក្រាវដែលមានទំហំ២២៦.៦៤ហិកតា។ ដូចនេះ កន្លែងអភិរក្សទាំងពីរនេះ បានធ្វើការគ្រប់គ្រងបន្ទាប់ពីសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មស ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយកន្លែងអភិរក្សបង្កើតឡើងក្នុងគោលបំណងដូចជា៖

- បង្កើនពូជត្រី ស្មៅ ផ្កាថ្ម និងភរីសត្វសមុទ្រគ្រប់ប្រភេទ
- ថែរក្សាការពារព្រៃកោងកាងដែលជាជម្រក ប្រភពចំណីរបស់ត្រី និងសត្វ
- ផ្ដល់ចំណេះដឹងដល់ប្រជាពលរដ្ឋឱ្យចេះស្រឡាញ់ថែរក្សា ការពារធនធានធម្មជាតិ
- ពិសេស ធនធានជលផល បរិស្ថាន និងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់។

តាមការចុះអង្កេតរបស់ក្រុមការងារ និងពិភាក្សាលើលក្ខណៈវិនិច្ឆ័យជាមួយគណៈកម្មការ និងសមាជិកសហគមន៍នេសាទនេះបានបញ្ជាក់ថា សហគមន៍នេសាទនេះបានសម្រេចបង្កើតកន្លែងអភិរក្សដែលពុំអនុញ្ញាតិទុកនេសាទ ឬកាណូតធ្វើការឆ្លងកាត់ក្នុងកន្លែងអភិរក្សនេះឡើយដែលជាកន្លែងសំខាន់បំផុតសម្រាប់ធ្វើការអភិរក្សធនធានជលផលដែលសមាជិកសហគមន៍នេសាទមានសុឆន្ទៈចង់ចូលរួមក្នុងការគ្រប់គ្រងធនធានជលផល ដើម្បីធានានូវប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានជលផល និងមានសារៈប្រយោជន៍សម្រាប់តម្រូវការផលត្រីរបស់ប្រជាពលរដ្ឋក្នុងសហគមន៍។ ដូចនេះ កន្លែងអភិរក្សចំនួន០២កន្លែង ដូចបានបញ្ជាក់ក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះកន្លែងអភិរក្ស | ទំហំ(ហត) | ប្រភេទនៃការអភិរក្ស |
|---|---|---|---|
| ១ | ព្រៃភក់ធំ | ៤០០ | កន្លែងអភិរក្សគ្រងឈាម |
| ២ | ឃ្លោងស្រែក្រាវ | ២២៦.៦៤ | ការអភិរក្សស្មៅ ផ្កាថ្ម និងត្រីគ្រប់ប្រភេទ |

កន្លែងអភិរក្សជាកត្តាចាំបាច់ដែលត្រូវរៀបចំកំណត់ព្រំប្រទល់បោះបង្គោលព្រំប្រទល់ ធ្វើប៉ាណូផ្សព្វផ្សាយក្ដាខៀនព័ត៌មាន បិទផ្សាយបទបញ្ញត្តិផ្សេងសម្រាប់កន្លែងអភិរក្ស សាងសង់រោងយាមសម្រាប់ក្រុមល្បាតបំពេញការងារ។

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះទីតាំង | ទំហំ (ហត) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| ១ | កន្លែងអភិរក្សព្រៃភក់ធំ | ៤០០ | • ប្រភេទត្រីសំខាន់<br>• ប្រភេទផ្កាថ្ម<br>• ប្រភេទសារាយ<br>• ប្រភេទពពួកល្មូន | • ផ្សព្វផ្សាយអ្នកពាក់ព័ន្ធ<br>• សិក្សាពីកន្លែងអភិរក្ស<br>• បង្គោលចំនួន០៦ដើម<br>•ធ្វើប៉ាណូផ្សព្វផ្សាយ<br>•សង់រោងយាម | ២០២២ | ២០២៤ |
| ២ | កន្លែងអភិរក្សឈ្លងស្វែក្រៅ | ២២៦.៦៤ | • ប្រភេទត្រីសំខាន់<br>• ប្រភេទផ្កាថ្ម<br>• ប្រភេទសារាយ<br>• ប្រភេទពពួកល្មូន | • ផ្សព្វផ្សាយអ្នកពាក់ព័ន្ធ<br>• សិក្សាពីកន្លែងអភិរក្ស<br>• បង្គោលចំនួន០៦ដើម<br>•ធ្វើប៉ាណូផ្សព្វផ្សាយ<br>•សង់រោងយាម | ២០២២ | ២០២៤ |

### គ.៦.ផែនការអភិវឌ្ឍន៍ការវិប្បកម្ម

ការចិញ្ចឹមត្រីជាទិសដៅដ៏សំខាន់របស់វិស័យជលផល ក្នុងការបង្កើនត្រីសាច់សម្រាប់ហូបចុករបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងសម្រាប់នាំចេញទៅទីផ្សារអន្តរជាតិ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន។ កន្លងមក សមាជិកសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មសចូលចិត្តចិញ្ចឹមក្រែងឈាម ។ ដូចនេះ ដើម្បីឆ្លើយតបនឹងតម្រូវការសមាជិកសហគមន៍នេសាទ ផែនការអភិវឌ្ឍន៍កាវិប្បកម្ម ក្រែងឈាមនឹងត្រូវបានរៀបចំក្នុងគោលបំណងដូចជា៖

- បង្កើនត្រីសាច់សម្រាប់ហូបចុករបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- បង្កើនប្រាក់ចំណូលដែលជួយស្ទួយសេដ្ឋកិច្ចគ្រួសារ
- កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត។

ឆ្លើយតបទៅនឹងការពង្រីកការអភិវឌ្ឍន៍កាវិប្បកម្ម គណៈកម្មការ និងសមាជិកសហគមន៍នេសាទបានរៀបចំផែនការអភិវឌ្ឍន៍ការចិញ្ចឹមត្រីដូចមានក្នុងតារាងខាងក្រោម៖

| ប្រភេទ | ចំនួន | ប្រភេទកូនត្រីពូជ | សកម្មភាព | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ស៊ុំ | ១៥ | ក្រែងឈាម | រៀបចំក្រុមចិញ្ចឹម | ១០/០២/២០២២ | ៣០/០២/២០២២ |
| | | | បណ្តុះបណ្តាលក្រុម | ០១/០៣/២០២២ | ២៥/០៣/២០២២ |
| | | | ផ្តល់ពូជ និងសម្ភារៈ | ០១/០៥/២០២២ | ២៥/០៥/២០២២ |
| | | | តាមដានការចិញ្ចឹម | ០១/០៦/២០២២ | ២០២៤ |

## គ.៧.ផែនការរៀបចំធនាគារក្ដាមសេះ

ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មស ជាសកម្មភាពចំបងដែលជួយពង្រីកមុខរបរដល់ប្រជានេសាទនៅក្នុងសហគមន៍ ជាពិសេស បានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត។ កន្លងមករដ្ឋបាលជលផល និងអង្គការដៃគូអភិវឌ្ឍន៍បានជួយបណ្ដុះបណ្ដាល អំពីបច្ចេកទេសចិញ្ចឹមសត្វ ការចិញ្ចឹមត្រី និងក្ដាមសេះលក្ខណៈគ្រួសារ ព្រមទាំងការចិញ្ចឹមជីវិតផ្សេងៗដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារក្នុងគោលបំណង៖

- ដើម្បីឱ្យប្រជាពលរដ្ឋមានមុខរបរ និងមានដើមទុនសំរាប់បង្កើនប្រាក់ចំណូល
- កាត់បន្ថយអត្រាការប្រាក់ខ្ពស់ និងខ្ចីប្រាក់ពីឈ្មួញ
- ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង។

គណៈកម្មការសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មស បានចាប់អារម្មណ៍ក្នុងការបង្កើតធនាគារក្ដាមសេះដោយមានសមាជិកចូលរួមដែលចែកជា២៥ក្រុមតូចៗ ក្នុងនោះ១ក្រុមមានចំនួន៥នាក់ ដោយប្រើប្រាស់វិធីសាស្ត្រជាលក្ខណៈជាក្រុម។ ចំពោះបែចិញ្ចឹម ត្រូវបានគ្រោងសាងសង់ជា២៥បែដែលក្នុង១បែមានទំហំ(៥មx៤មx២,៥ម) ផែនការអភិវឌ្ឍន៍មុខរបរចិញ្ចឹមជីវិតមានក្នុងតារាងខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ឯកតា | ចំនួន | ថវិកា (រៀល) | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| ធនាគារក្ដាមសេះតាមបច្ចេកទេសជាលក្ខណៈជាក្រុម | ផ្សព្វផ្សាយទស្សនៈដល់សហគមន៍ | នាក់ | ១៤៧ | ១០០ ០០០ | ២០២២ | ២០២៤ |
| | ជ្រើសរើស និងរៀបចំក្រុម | ក្រុម | ២៥ | ៥០ ០០០ | | |
| | បោះឆ្នោតជ្រើសរើសប្រធាន-អន | នាក់ | ០៣ | ២០០ ០០០ | | |
| | បង្កើតគោលការណ៍-បទបញ្ជាផ្ទៃក្នុង | ច្បាប់ | ០៥ | ២០០ ០០០ | | |
| | បណ្ដុះបណ្ដាលពីឯកសារ និងថវិកា | វគ្គ | ០៦ | ៦០០ ០០០ | | |
| | រៀបចំបែ | បែ | ២៥ | ៣ ០០០ ០០០ | | |
| | ផ្ដល់ទុន(៣០០០០០៛/នាក់) | រៀល | ២៥ | ៧ ៥០០ ០០០ | | |
| | ត្រួតពិនិត្យតាមដានការអនុវត្តន៍ | ក្រុម | ២៥ | ១ ៥០០ ០០០ | | |

## គ.៨.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ

ពេលបច្ចុប្បន្ន សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មស បានគ្រោងផែនការរៀបចំកន្លែងកំសាន្តនៅមាត់សមុទ្រដែលជាដែននេសាទរបស់សហគមន៍នេសាទ។ ការរៀបចំកន្លែងកំសាន្តអាចជួយកាត់បន្ថយអត្រាចំណាកស្រុករបស់សមាជិកសហគមន៍នេសាទ និងកាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង ព្រមទាំងបានចូលរួមចំណែកក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព។ ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍តំបន់ឆ្នេរសមុទ្រថ្មស ក្នុងគោលបំណងដូចជា៖

- បង្កើនប្រាក់ចំណូលដែលជួយស្តួយសេដ្ឋកិច្ចគ្រួសារ
- ជួយកាត់បន្ថយអត្រាចំណាកស្រុករបស់សមាជិកសហគមន៍នេសាទ
- កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត។
- ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង។

ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទមានដូចជា៖

| ប្រភេទមុខរបរ | សកម្មភាព | ឯកតា | ចំនួន | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| រៀបចំកន្លែងកំសាន្តសម្រាប់សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មស | ផ្សព្វផ្សាយទស្សនៈដល់សមាជិក | នាក់ | ១២០ | ២០២២ | ២០២៤ |
| | ការរៀបចំក្រុមសម្រាប់អនុវត្ត | ក្រុម | ១ | | |
| | បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង | ច្បាប់ | ៥ | | |
| | បណ្តុះបណ្តាលពីការរៀបចំឯកសារ | វគ្គ | ៩ | | |
| | កន្លែងចំអិនអាហារ(១០មx២០ម) | កន្លែង | ១ | | |
| | រៀបចំកន្លែងអង្គុយតូចៗ(៦មx៨ម) | កញ្ចុះ | ១០ | | |
| | កន្លែងលក់សំបុត្រ(៥មx៨ម) | កន្លែង | ១ | | |
| | ការិយាល័យធ្វើការងារ(១០មx២០ម) | កន្លែង | ១ | | |
| | ត្រួតពិនិត្យតាមដាន | លើក | ២៥ | | |

### គ.៩.ផែនការពង្រីក និងអភិវឌ្ឍន៍មុខរបរចិញ្ចឹមជីវិតបន្ថែម

ការពង្រីក និងអភិវឌ្ឍន៍មុខរបរចិញ្ចឹមជីវិតបន្ថែមដល់សមាជិកសហគមន៍នេសាទ ជាសកម្មភាពចំបងដែលអាចជួយដល់ការរស់នៅរបស់ប្រជានេសាទក្នុងគោលបំណងដូចជា៖

- ដើម្បីឱ្យប្រជាពលរដ្ឋមានមុខរបរ និងមានដើមទុនសំរាប់បង្កើនប្រាក់ចំណូល
- កាត់បន្ថយអត្រាការប្រាក់ខ្ពស់ និងខ្ចីប្រាក់ពីឈ្មួញ។

ផែនការពង្រីក និងអភិវឌ្ឍន៍មុខរបរចិញ្ចឹមជីវិតបន្ថែម ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(រៀល) | អ្នកចូលរួម | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ១ | ពិនិត្យទីតាំងនិងពិភាក្សាតម្រូវការ | ១ ០០០ ០០០ | សមាជិក និង អ្នកពាក់ព័ន្ធ | ០១/៥/២០២២ | ០៥/៥/២០២២ |
| ២ | រៀបចំក្រុមប្រភេទមុខរបរបន្ថែម | ២០០ ០០០ | សមាជិក | ១០/៥/២០២២ | ១៦/៥/២០២២ |
| ៣ | បណ្តុះបណ្តាលបច្ចេកទេស | ១ ០០០ ០០០ | សមាជិក | ២០/៥/២០២២ | ១០/៦/២០២២ |
| ៤ | ទិញសម្ភារៈសម្រាប់អនុវត្ត | ៤ ០០០ ០០០ | សមាជិក | ១៥/៦/២០២២ | ២០/៦/២០២២ |
| ៥ | ដំណើរការផលិត | ៧ ០០០ ០០០ | សមាជិក | ២០/៦/២០២២ | ២០២៤ |
| ៦ | ពិនិត្យ និងតាមដានការអនុវត្ត | ៥០០ ០០០ | អ្នកពាក់ព័ន្ធ | ៣០/៦/២០២២ | ២០២៤ |

## គ.១០.ផែនការគ្រប់គ្រងកាកសំណល់ផ្លាស្ទិក និងសម្រាមផ្សេងៗ

ផែនការគ្រប់គ្រងកាកសំណល់ផ្លាស្ទិក និងសម្រាមផ្សេងៗក្នុងសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មស ត្រូវបានរៀបចំឡើងដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(រៀល) | ថ្ងៃ/ខែ/ឆ្នាំចាប់ផ្ដើម | ថ្ងៃ/ខែ/ឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ១ | ពិភាក្សា និងរៀបចំឯកសារ | ៥០០ ០០០ | ០៤/០២/២០២២ | ១០/០២/២០២២ |
| ២ | បោះពុម្ពផ្ទាំងរូប និងខិតបណ្ណ័ផ្សព្វផ្សាយ | ១ ៥០០ ០០០ | ២៥/០២/២០២២ | ២៨/០២/២០២២ |
| ៣ | ផ្សព្វផ្សាយដល់សមាជិកចំនួន៤ដង/ឆ្នាំ | ២០០ ០០០ | ៣០/០៣/២០២២ | ២០២៤ |

## គ.១១.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ

ជាទូទៅ បេក្ខជនដែលឈរឈ្មោះជាគណៈកម្មការសហគមន៍នេសាទត្រូវបានបញ្ជាក់ពីគុណភាព និងចំណេះដឹងដូចជា៖ ចេះអាន សរសេរ អាកប្បកិរិយាសមរម្យដោយឯកភាពពីសមាជិកសហគមន៍នេសាទ ហើយការរៀបចំបោះឆ្នោតជ្រើសរើសជាគណៈកម្មការ ដោយបានប្រើនីតិវិធីស្របតាមគោលការណ៍ណែនាំសហគមន៍នេសាទដែលបានអនុម័តដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។ ជាក់ស្ដែង គណៈកម្មការសហគមន៍នេសាទនេះ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយត្រឹមត្រូវ និងយុត្តិធម៌ដែលមានសំឡេងគាំទ្រច្រើនជាងគេ ហើយញឹកញាប់សមាសភាពគណៈកម្មការសហគមន៍នេសាទគឺ ថ្មីដែលសមត្ថភាពរបស់សមាជិកគណៈកម្មការមានកំរិតលើការយល់ដឹងពីលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ជំនាញសម្របសម្រួលទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ និងការរៀបផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ។ គោលបំណងនៃការបណ្ដុះបណ្ដាលដូចជា៖

- គណៈកម្មការសហគមន៍នេសាទនឹងអាចអនុវត្តសកម្មភាពក្នុងការងារ
- យល់ពីតួនាទី និងភារកិច្ចរបស់ពួកគាត់
- បង្កើនសាមគ្គីភាព និងការទំនាក់ទំនងល្អជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធ។

ផែនការបណ្ដុះបណ្ដាលដល់សមាសភាពគណៈកម្មការសហគមន៍នេសាទ មានក្នុងតារាងខាងក្រោម៖

| លរ | សកម្មភាព | ចំនួន | ថ្ងៃ/ខែ/ឆ្នាំចាប់ផ្ដើម | ថ្ងៃ/ខែ/ឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ១ | បណ្ដុះបណ្ដាលរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាលរបាយការណ៍ និងរៀបចំទុកឯកសារ | ១លើក | ២០២២ | ២០២២ |
| ២ | បណ្ដុះបណ្ដាលការគ្រប់គ្រងថវិកា | ១លើក | ២០២២ | ២០២២ |
| ៣ | បណ្ដុះបណ្ដាលការដោះស្រាយទំនាស់ | ១លើក | ២០២៣ | ២០២៣ |
| ៤ | បណ្ដុះបណ្ដាលជំនាញក្នុងការសម្របសម្រួល | ១លើក | ២០២៣ | ២០២៣ |
| ៥ | បណ្ដុះបណ្ដាលការរៀបចំផែនការ | ១លើក | ២០២៤ | ២០២៤ |

 គ.១២.ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ

ដើម្បីធានាការប្រើប្រាស់ធនធានជលផលពេលអនាគត និងបានយូរអង្វែងនោះ គប្បីធ្វើការផ្សព្វផ្សាយអំពីច្បាប់ស្តីពី ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីឱ្យមានការយល់ដឹងគ្រប់គ្រាន់ក្នុងការចូលរួមចំណែកក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព ។ ការផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធក្នុងគោលបំណងដូចជា៖

- បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍
- កាត់បន្ថយសកម្មភាពបទល្មើសនេសាទក្នុងសហគមន៍។

ផែនការសកម្មភាពមានដូចខាងក្រោម៖

| ល.រ | សកម្មភាព | អ្នកទទួលខុសត្រូវ | រយៈពេលអនុវត្ត ២០២២-២០២៤ | | | តម្លៃប៉ាន់ស្មាន (គិតជារៀល) | ប្រភពទុន |
|---|---|---|---|---|---|---|---|
| | | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | | |
| ១ | ផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ | រដ្ឋបាលជលផល | ៤ | ៤ | ៤ | ២ ៥០០ ០០០ | រដ្ឋបាលជលផល ដៃគូអភិវឌ្ឍន៍ ឃុំ-សង្កាត់ |
| ២ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | ស.ន | ៤ | ៤ | ៤ | ១ ០០០ ០០០ | រដ្ឋបាលជលផល ដៃគូអភិវឌ្ឍន៍ ឃុំ-សង្កាត់ |

គ.១៣.ផែនការបង្កើតស្នាក់ការ និងការបំពាក់សម្ភារៈ

ពេលបច្ចុប្បន្ន សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មស ទើបបង្កើតស្នាក់ការសហគមន៍នេសាទដោយថវិកាសហគមន៍ផ្ទាល់តែនៅខ្វះថវិកាសម្រាប់បំពាក់សម្ភារៈក្នុងស្នាក់ការនេះ។ ដូចនេះ គណៈកម្មការខិតខំស្វែងរកថវិកាដើម្បីបំពាក់សម្ភារៈសម្រាប់បំពេញការងារជារៀងរាល់ថ្ងៃដូចជា៖ ការងារទំនាក់ទំនងជាមួយក្រុមការងារផ្សេងៗ ឬភ្ញៀវទេសចរណ៍ជាដើម។ ដូច្នេះ ផែនការបំពាក់សម្ភារៈមួយចំនួនដូចជា៖ តុសម្រាប់ធ្វើការងារ កៅអី ផែនទីសហគមន៍នេសាទ តុសម្រាប់ប្រជុំ និងទូឯកសារមានដូចខាងក្រោម៖

| ល.រ | សកម្មភាព | ទីតាំងគម្រោង | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ | តម្លៃប៉ាន់ស្មាន (រៀល) | ប្រភពទុន |
|---|---|---|---|---|---|---|
| ១ | ការបង្កើតស្នាក់ការ | ស.ន | ២០២២ | ២០២៤ | ១១ ០០០ ០០០ | អង្គការដៃគូ សប្បុរសជន |
| ២ | ការបំពាក់សម្ភារៈ | ស.ន | ២០២២ | ២០២៤ | ៤ ០០០ ០០០ | |

### គ.១៤.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ

ដោយឡែក គណៈកម្មការសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មស ត្រូវដើរតួនាទីសំខាន់ក្នុងការស្វែងរកប្រាក់ចំណូលពីប្រភពផ្សេងៗដូចជា៖ ភាគទានពីសមាជិកសហគមន៍ អង្គការដៃគូអភិវឌ្ឍន៍ សប្បុរសជន ក្រុមប្រឹក្សាឃុំ-សង្កាត់និងការធ្វើទស្សនៈកិច្ចរបស់ភ្ញៀវមកក្នុងសហគមន៍នេសាទ។

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ប្រភេទចំណូល | សកម្មភាព | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ | ចំណូល (រៀល) |
|---|---|---|---|---|---|
| ១ | ភាគប្រចាំឆ្នាំពីសមាជិកសហគមន៍ | ផ្សព្វផ្សាយ និងបណ្ណភាគទាន | ២០២២ | ២០២៤ | ២ ០០០ ០០០ |
| ២ | ពីអ្នកនេសាទខាងក្រៅ ឬអ្នកមិនមែនជាសមាជិក | ចេញបណ្ណភាគទាន | ២០២២ | ២០២៤ | ២ ៥០០ ០០០ |
| ៣ | សប្បុរសជន និងអង្គការដៃគូអភិវឌ្ឍន៍ | • បង្កើតមុតរបរ<br>• ជាថវិកាផ្ទាល់ | ២០២២ | ២០២៤ | ២ ៥០០ ០០០ |
| ៤ | ក្រុមប្រឹក្សាសង្កាត់ | ធនធានធម្មជាតិ | ២០២២ | ២០២៤ | ២ ០០០ ០០០ |

### ឃ.យុទ្ធសាស្ត្រ

នៅក្នុងសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មស ត្រូវរៀបចំយុទ្ធសាស្ត្រមួយចំនួន ដើម្បីឱ្យការអនុវត្តផែនការទទួលបានជោគជ័យ។ យុទ្ធសាស្ត្រទាំងមានដូចខាងក្រោម៖

- គណៈកម្មការត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការរួមមាន៖ សមាជិកសហគមន៍នេសាទ ចាស់ទុំដែលមានបទពិសោធន៍ និងចំណេះដឹងល្អជាពិសេសអំពីបញ្ហានេសាទ។
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា៖ ការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃកោងកាង កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម។
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ។
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់។
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ។

- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ។
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ។
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍។
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ។
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ។
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

# តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍តំបន់ឆ្នេរសមុទ្រថ្មសរយៈពេល០៣ឆ្នាំ

## (ខែកុម្ភៈ ឆ្នាំ២០២២ ដល់ ខែធ្នូ ឆ្នាំ២០២៤)

| ប្រភេទផែនការ/សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (រៀល) | ប្រភពជំនួយ | ពេលផ្ដើម | ពេលបញ្ចប់ |
|---|---|---|---|---|---|
| ១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ | • កាត់បន្ថយទំនាស់នេសាទក្នុងកន្លែងនេសាទ<br>• កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់<br>• សហគមន៍នឹងអនុវត្តន៍ប្រកាសស្ដីពីការប្រើប្រាស់ឧបករណ៍ | ១ ៨០០ ០០០ | | ២០២២ | ២០២៤ |
| ១.១.ប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារក្នុង១ឆ្នាំ/៤ដង | សមាជិកនឹងយល់ដឹងពីការការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារ | ១ ៨០០ ០០០ | អង្គការដៃគូ សប្បុរសជន រដ្ឋាភិបាល | ២០២២ | ២០២៤ |
| ១.២.ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | អ្នកពាក់ព័ន្ធនឹងចូលរួមផ្សព្វផ្សាយបន្តដល់សហគមន៍ | | | | |
| ១.៣.ត្រួតពិនិត្យនិងតាមដាន | គណៈកម្មការ និងសមាជិកចូលរួមឃ្លាំមើលនិងរាយការណ៍ | | | | |
| ២.ផែនការស្រង់ស្ថិតិឧបករណ៍ ទូកកាណូត និងផលនេសាទ | | ៦ ០០០ ០០០ | | | |
| ២.១.បង្កើតកម្រងបញ្ជីសំណួរ | កម្រងបញ្ជីសំណួរនឹងត្រូវបានបង្កើតឡើង | ៥០០ ០០០ | អង្គការដៃគូ សប្បុរសជន រដ្ឋាភិបាល | ២០២២ | ២០២៤ |
| ២.២.បណ្ដុះបណ្ដាលក្រុមការងារ | ក្រុមការងារនឹងត្រូវបានបណ្ដុះបណ្ដាល | ១ ៥០០ ០០០ | | | |
| ២.៣.ចុះស្រង់ស្ថិតិឧបករណ៍នេសាទ | ស្ថិតិឧបករណ៍នេសាទនឹងត្រូវបានចុះស្រង់ | ៣ ៥០០ ០០០ | | | |
| ២.៤.ចងក្រងទិន្នន័យ | ទិន្នន័យនឹងត្រូវបានចងក្រង | ៥០០ ០០០ | | | |
| ៣.ផែនការចុះល្បាត | • ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់<br>• សមាជិកអាចទទួលបានផលនេសាទពីកន្លែងនេសាទសហគមន៍<br>• គ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព | ១២ ០០០ ០០០ | | | |
| ៣.១.ប្រជុំពិភាក្សាលើការរៀបចំផែនការល្បាត | ផែនការល្បាតបានពិគ្រោះយោបល់ និងរៀបចំសម្រាប់អនុវត្ត | ៥០០ ០០០ | អង្គការដៃគូ សប្បុរសជន រដ្ឋាភិបាល | ២០២២ | ២០២៤ |
| ៣.២.រៀបចំមធ្យោបាយ និងសម្ភារៈ | មធ្យោបាយ និងសម្ភារៈបានគ្រោងនិងរៀបចំ | ៩ ០០០ ០០០ | | | |
| ៣.៣.ប្រជុំផ្សព្វផ្សាយផែនការល្បាតដល់អ្នកពាក់ព័ន្ធ | ផែនការល្បាតត្រូវបានផ្សព្វផ្សាយ | ១ ០០០ ០០០ | | | |
| ៣.៤.អនុវត្តផែនការចុះល្បាត | ផែនការចុះល្បាតត្រូវបានចុះអនុវត្ត | ១ ៥០០ ០០០ | | | |
| ៤.ផែនការបោះព្រំប្រទល់សហគមន៍នេសាទជាថ្មី | | ៦ ៨០០ ០០០ | | | |
| ៤.១.ការងារប្រជុំពិភាក្សាកំណត់ទំហំបង្គោល | ការកំណត់ទំហំបង្គោល នឹងត្រូវបានប្រជុំពិភាក្សា | ២០០ ០០០ | អង្គការដៃគូ សប្បុរសជន រដ្ឋាភិបាល | ២០២២ | ២០២៤ |
| ៤.២.រៀបចំ និងសាងសង់បង្គោលចំនួន១៦ដើម | បង្គោលចំនួន១៦ដើមនឹងត្រូវបានរៀបចំ និងសាងសង់ | ៦ ០០០ ០០០ | | | |
| ៤.៣.ការបោះបង្គោលព្រំប្រទល់សហគមន៍នេសាទ | ចំនួន១៦ដើមបង្គោលនឹងត្រូវបានបោះជាព្រំប្រទល់សហគមន៍នេសាទ | ២ ០០០ ០០០ | | | |

| | | | | | |
|---|---|---|---|---|---|
| ៤.៤.ត្រួតពិនិត្យ និងតាមការអនុវត្ត | ត្រួតពិនិត្យ និងតាមការអនុវត្តនឹងត្រូវបានធ្វើ | ៥០០ ០០០ | | | |
| **៥.ផែនការរៀបចំកន្លែងអភិរក្សព្រៃកាត់ធំ និងឃ្លោងស្រែត្រាវ** | •ប្រភេទត្រីមេពូជ និងវារីសត្វគ្រប់ប្រភេទត្រូវបានធ្វើការអភិរក្ស<br>•ប្រភេទព្រៃកោងកាងនឹងត្រូវបានការពារ<br>•ប្រជាជននឹងយល់ដឹងពីសារៈសំខាន់កន្លែងអភិរក្សនឹងចូលរួមថែរក្សា | **១០ ៤០០ ០០០** | | | |
| ៥.២.ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | អ្នកពាក់ព័ន្ធនឹងត្រូវបានផ្សព្វផ្សាយពីការបោះបង្គោល | ២០០ ០០០ | អង្គការដៃគូ<br>សប្បុរសជន<br>រដ្ឋាភិបាល | ២០២២ | ២០២៤ |
| ៥.១.បោះបង្គោលស៊ីម៉ង់កន្លែងអភិរក្សរាវតាប៉ិ | បង្គោលចំនួន១២ដើម និងបានបោះនៅកន្លែងអភិរក្សជាមួយផែនទីសំគាល់ | ៣ ០០០ ០០០ | | | |
| ៥.៣.ផលិតផ្ទាំងប៉ាណូផ្សព្វផ្សាយ | ចំនួន០២ស្លាកផ្ទាំងប៉ាណូនឹងបោះសម្រាប់ផ្សព្វផ្សាយ | ១ ២០០ ០០០ | | | |
| ៥.៤.សង់រោងយាម | រោងយាមចំនួន០១ត្រូវបានសាងសងនៅកន្លែងអភិរក្សទំហំ៤មx៥ម | ៥ ៤០០ ០០០ | | | |
| ៥.៥.ត្រួតពិនិត្យតាមដាន | ការរៀបចំកន្លែងអភិរក្សនឹងត្រូវបានធ្វើការត្រួតពិនិត្យតាមដាន | ២០០ ០០០ | | | |
| **៦.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម** | •បង្កើនត្រីសាច់សម្រាប់ហូបចុកក្នុងមូលដ្ឋាន<br>•រកប្រាក់ចំណូលជួយសម្រួលសេដ្ឋកិច្ចគ្រួសារ<br>•កាត់បន្ថយសម្ពាធនេសាទលើធនធានជលផលឬសកំរិត | **២ ០០០ ០០០** | | | |
| ៦.១.រៀបចំក្រុមចិញ្ចឹមត្រីគ្រងឈាម | ចំនួន១៥ក្រុមចិញ្ចឹមនឹងត្រូវបានរៀបចំ | ២ ០០០ ០០០ | ដៃគូរអភិវឌ្ឍន៍<br>សប្បុរសជន<br>រដ្ឋាភិបាល | ២០២២ | ២០២៤ |
| ៦.២.បណ្តុះបណ្តាលក្រុម | ក្រុមចិញ្ចឹមនឹងត្រូវបានបណ្តុះបណ្តាលក្រុម | | | | |
| ៦.៣.ផ្តល់ពូជ និងសម្ភារៈ | នឹងផ្តល់ពូជ និងសម្ភារៈក្រុមចិញ្ចឹម | | | | |
| ៦.៣.តាមដានការចិញ្ចឹម | ការចិញ្ចឹមនឹងត្រូវបានពិនិត្យ និងតាមដាន | | | | |
| **៧.ផែនការអភិវឌ្ឍន៍ធនាគារក្តាមសេះ** | •ដើម្បីឱ្យប្រជាពលរដ្ឋមានមុខរបរនិងមានដើមទុនសំរាប់បង្កើនប្រាក់ចំណូល<br>•កាត់បន្ថយអត្រាការប្រាក់ខ្ពស់និងខ្ចីប្រាក់ពីឈ្មួញ<br>•ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង | **១៦ ៦០០ ០០** | | ២០២២ | ២០២៤ |
| ៧.១.ផ្សព្វផ្សាយទស្សនៈដល់សហគមន៍ | អ្នកពាក់ព័ន្ធនឹងត្រូវផ្សព្វផ្សាយ | ១០០ ០០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២៤ |
| ៧.២.ជ្រើសរើសក្រុមធនាគារក្តាមសេះ | ចំនួន២៥ក្រុមធនាគារក្តាមសេះត្រូវបានជ្រើសរើស(០៥នាក់/ក្រុម) | ៤០០ ០០០ | | | |
| ៧.៣.បោះឆ្នោតជ្រើសរើសប្រធាន អនុប្រធាន | ប្រធាន អនុប្រធានត្រូវបានជ្រើសរើសបោះឆ្នោត | ២០០ ០០០ | | | |
| ៧.៤.បង្កើតគោលការណ៍និងបទបញ្ជាផ្ទៃក្នុង | គោលការណ៍និងបទបញ្ជាផ្ទៃក្នុងត្រូវបានបង្កើតឡើង | ២០០ ០០០ | | | |
| ៧.៥.បណ្តុះបណ្តាលក្រុមពីឯកសារ និងថវិកា | សមាជិកធនាគារក្តាសេះត្រូវបានបណ្តុះបណ្តាល | ៦០០ ០០០ | | | |
| ៧.៦.រៀបចំបែ | ចំនួន២៥បែត្រូវបានរៀបចំ( ទំហំបែ=៥ម x ៤មx ២,៥ម ) | ៣ ០០០ ០០០ | | | |
| ៧.៧.ផ្តល់ទុន | ទុនត្រូវផ្តល់ដល់សមាជិកធនាគារក្តាមសេះម្នាក់ៗ | ៧ ៥០០ ០០០ | | | |
| ៧.៨.ត្រួតពិនិត្យតាមដានការអនុវត្តន៍ | ត្រួតពិនិត្យតាមដាននឹងត្រូវបានអនុវត្ត | ១ ៥០០ ០០០ | | | |
| **៨.ផែនការអភិវឌ្ឍន៍កន្លែងដំកំសាន្តរបស់សហគមន៍នេសាទ** | •បង្កើនប្រាក់ចំណូលដែលជួយសម្រួលសេដ្ឋកិច្ចគ្រួសារ<br>•ជួយកាត់បន្ថយអត្រាចំណាកស្រុករបស់សមាជិកសហគមន៍នេសាទ<br>•កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលឬសកំរិត | **២៦ ៤០០ ០០០** | | | |

| | | | | | |
|---|---|---|---|---|---|
| | • ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង | | | | |
| ៨.១.ផ្សព្វផ្សាយទស្សនៈដល់សមាជិក | សមាជិកសហគមន៍ចំនួន១៤៧នាក់ ត្រូវបានផ្សព្វផ្សាយ | ២០០ ០០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២៤ |
| ៨.២.ការរៀបចំក្រុមសម្រាប់អនុវត្ត | ចំនួន១ក្រុមសម្រាប់កន្លែងកំសាន្តត្រូវបានបង្កើតឡើង | ១០០ ០០០ | | | |
| ៨.៣.បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង | គោលការណ៍ និងបទបញ្ជាផ្ទៃក្នុងត្រូវបានបង្កើតឡើង | ៥០០ ០០០ | | | |
| ៨.៤.បណ្តុះបណ្តាលពីការរៀបចំឯកសារ | ចំនួន៩វគ្គ ត្រូវបានរៀបចំ និងបណ្តុះបណ្តាល | ២ ៥០០ ០០០ | | | |
| ៨.៥.កន្លែងចំអិននិងបែងចែកអាហារ | កន្លែងចំអិន អាហារ ត្រូវបានរៀបចំ( ទំហំ=១០ម×២០ម ) | ៥ ៥០០ ០០០ | | | |
| ៨.៦.រៀបចំកន្លែងអង្គុយតូចៗ(កញ្ចុះ) | កញ្ចុះអង្គុយនីមួយៗដែលទំហំ៦ម×៨ម ចំនួន២០កញ្ចុះត្រូវបានរៀបចំ | ១០ ០០០ ០០០ | | | |
| ៨.៧.កន្លែងលក់សំបុត្រ | កន្លែងលក់សំបុត្រត្រូវបានរៀបចំ( ទំហំ៥ម×៨ម ) | ២ ០០០ ០០០ | | | |
| ៨.៨.ការិយាល័យធ្វើការងារ | ការិយាល័យចំនួន០១កន្លែងត្រូវបានបង្កើតឡើង( ទំហំ១០ម×២០ម ) | ៤ ០០០ ០០០ | | | |
| ៨.៩.ត្រួតពិនិត្យតាមដាន | ការអនុវត្តការកន្លែងកំសាន្តរបស់សហគមន៍នេសាទត្រួតពិនិត្យនិងតាមដាន | ១ ៥០០ ០០០ | | | |
| **៩.ផែនការពង្រីក និងអភិវឌ្ឍន៍មុខរបរចិញ្ចឹមជីវិតបន្ថែម** | • ដើម្បីឱ្យប្រជាពលរដ្ឋមានមុខរបរ និងមានដើមទុនសំរាប់បង្កើនប្រាក់ចំណូល<br>• កាត់បន្ថយអត្រាការប្រាក់ខ្ពស់ និងខ្ចីប្រាក់ពីឈ្មួញ | **១៣ ៧០០ ០០០** | | | |
| ៩.១.ពិនិត្យទីតាំង និងពិភាក្សាតម្រូវការ | ពិនិត្យទីតាំង និងពិភាក្សាតម្រូវការនឹងត្រូវបានធ្វើ | ១ ០០០ ០០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២៤ |
| ៩.២.រៀបចំក្រុមតាមប្រភេទមុខរបរបន្ថែម | រៀបចំក្រុមតាមប្រភេទមុខរបរបន្ថែមនឹងត្រូវបានធ្វើ | ២០០ ០០០ | | | |
| ៩.៣.បណ្តុះបណ្តាលបច្ចេកទេស | បណ្តុះបណ្តាលបច្ចេកទេសនឹងត្រូវបានធ្វើ | ១ ០០០ ០០០ | | | |
| ៩.៤.ទិញសម្ភារៈសម្រាប់អនុវត្ត | ទិញសម្ភារៈសម្រាប់អនុវត្តនឹងត្រូវបានធ្វើ | ៤ ០០០ ០០០ | | | |
| ៩.៥.ដំណើរការផលិត | ដំណើរការផលិតនឹងត្រូវបានធ្វើ | ៧ ០០០ ០០០ | | | |
| ៩.៦.ការពិនិត្យ និងតាមដានការអនុវត្ត | ការពិនិត្យ និងតាមដានការអនុវត្តនឹងត្រូវបានធ្វើ | ៥០០ ០០០ | | | |
| **១០.ផែនការគ្រប់គ្រងកាកសំណល់ផ្លាស្ទិក និងសម្រាមផ្សេងៗ** | | **២ ២០០ ០០០** | | | |
| ១០.១.ពិភាក្សា និងរៀបចំឯកសារ | ពិភាក្សា និងរៀបចំឯកសារនឹងត្រូវបានធ្វើ | ៥០០ ០០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២៤ |
| ១០.២.បោះពុម្ពផ្ទាំងរូប និងខិតបណ្ណ័ផ្សព្វផ្សាយ | បោះពុម្ពផ្ទាំងរូប និងខិតបណ្ណ័ផ្សព្វផ្សាយនឹងត្រូវបានធ្វើ | ១ ៥០០ ០០០ | | | |
| ១០.៣.ផ្សព្វផ្សាយដល់សមាជិកចំនួន៤ដង/ឆ្នាំ | ផ្សព្វផ្សាយដល់សមាជិកចំនួន៤ដង/ឆ្នាំនឹងត្រូវបានធ្វើ | ២០០ ០០០ | | | |
| **១១.ការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍** | • គណៈកម្មការនឹងអាចអនុវត្តសកម្មភាពក្នុងការងារ<br>• យល់ពីតួនាទី និងភារកិច្ចរបស់ពួកគាត់និង<br>• បង្កើនសាមគ្គីភាព និងការទំនាក់ទំនងល្អជាមួយអ្នកពាក់ព័ន្ធ | **១ ៧០០ ០០០** | | | |
| ១១.១.បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ សរសេររបាយការណ៍ និងលិខិតរដ្ឋបាល | កំណត់ហេតុ សរសេររបាយការណ៍និងលិខិតរដ្ឋបាលនឹងត្រូវបានបណ្តុះបណ្តាល | ៤០០.០០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២២ |
| ១១.២.បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ការគ្រប់គ្រងថវិកានឹងត្រូវបានបណ្តុះបណ្តាល | ៣០០ ០០០ | | ២០២២ | ២០២២ |
| ១១.៣.បណ្តុះបណ្តាលការដោះស្រាយទំនាស់ | វិធីសាស្ត្រដោះស្រាយទំនាស់នឹងត្រូវបានបណ្តុះបណ្តាល | ៤០០ ០០០ | | ២០២៣ | ២០២៣ |

| | | | | | |
|---|---|---|---|---|---|
| ១១.៤.បណ្តុះបណ្តាលជំនាញក្នុងការសម្របសម្រួល | ជំនាញសម្របសម្រួលនឹងត្រូវបានបណ្តុះបណ្តាល | ២០០ ០០០ | | ២០២៣ | ២០២៣ |
| ១១.៥.បណ្តុះបណ្តាលការរៀបចំផែនការ | ការរៀបចំផែនការ នឹងត្រូវបានបណ្តុះបណ្តាល | ៤០០ ០០០ | | ២០២៤ | ២០២៤ |
| **១២.ផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ** | • ង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ<br>• កាត់បន្ថយសកម្មភាពបទល្មើសនេសាទ | **៣ ៥០០ ០០០** | | | |
| ១២.១.ផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ | សមាជិកសហគមន៍នឹងផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋាន | ១ ៥០០ ០០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២៤ |
| ១២.២.ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | សមាជិកសហគមន៍នឹងត្រូវបានផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | ២ ០០០ ០០០ | | | |
| **១៣.ផែនការបង្កើតស្លាកការ និងការបំពាក់សម្ភារៈ** | | **១៥ ០០០ ០០០** | | | |
| ១៣.១.ការបង្កើតស្លាក់ | ការបង្កើតស្លាក់នឹងត្រូវបានអនុវត្ត | ១១ ០០០ ០០០ | អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២៤ |
| ១៣.១.ការបំពាក់សម្ភារៈ | សម្ភារៈកៅអីនិងទូឯកសានឹងត្រូវបានបំពាក់ | ៤ ០០០ ០០០ | | | |
| **១៤.ផែនការថវិកាសម្រាប់ទ្រទ្រង់សហគមន៍នេសាទ** | | **៨ ០០០ ០០០** | | | |
| ១៤.១.ភាគប្រចាំឆ្នាំពីសមាជិកសហគមន៍ | ភាគប្រចាំឆ្នាំពីសមាជិកសហគមន៍ | ២ ០០០ ០០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២៤ |
| ១៤.២.ពីអ្នកនេសាទខាងក្រៅឬអ្នកមិនមែនជាសមាជិក | ពីអ្នកនេសាទខាងក្រៅឬអ្នកមិនមែនជាសមាជិក | ២ ៥០០ ០០០ | | | |
| ១៤.៣.អំណោយពីសប្បុរសជន និងអង្គការដៃគូ | សប្បុរសជននិងអង្គការដៃគូអភិវឌ្ឍន៍ | ២ ៥០០ ០០០ | | | |
| ១៤.៤.ក្រុមប្រឹក្សាសង្កាត់-ឃុំ | មូលនិធិរបស់សង្កាត់ | ២ ០០ ០០០ | | | |

សូមគោរពជូន
លោកមេឃុំថ្មស
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ.......ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
..........ថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០២១
**ប្រធានគណៈកម្មការសហគមន៍នេសាទ**
**តំបន់ឆ្នេរសមុទ្រថ្មស**

លេខ:......../២១.
បានឃើញ និង គោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផលថ្មស
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ.......ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០២១
**មេឃុំថ្មស**
**អ៊ិក កួន**

បានឃើញ និង គោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលបូទុមសាគរ
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ថ្ងៃទី.......ខែ........ ឆ្នាំ២០២១
**នាយសង្កាត់រដ្ឋបាលជលផលថ្មស**

បានឃើញ និង គោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលកោះកុង
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ.......ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០២១
**នាយផ្នែករដ្ឋបាលជលផលបូទុមសាគរ**

លេខ:.......
បានឃើញ និង គោរពជូន
លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកោះកុង
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ.......ខែ.......ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
កោះកុង ថ្ងៃទី ០៥ ខែសីហា ឆ្នាំ ២០២១
**នាយខណ្ឌរដ្ឋបាលជលផលកោះកុង**

លេខ..........
បានឃើញ និង គោរពជូន
ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល
ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ
ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
កោះកុង ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០២១
**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកោះកុង**
**អ៊ុំ ម៉េងលាង**

លេខ.........
បានឃើញ និងឯកភាព
ថ្ងៃ.......ខែ.......ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី......ខែធ្នូ ឆ្នាំ២០២១
**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**
**ពុំ សុថា**